Tax Ombudsman

## របៀបទាក់ទងមកយើង

**taxombudsman.gov.au**

**1300 44 88 29** (ថ្លៃហៅទូរសព្ទតាមតំបន់)

**enquiries@taxombudsman.gov.au**

**GPO Box 551, Sydney NSW 2001**

សម្រាប់**សេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ដោយឥតគិត**ថ្លៃ សូមហៅទូរសព្ទទៅលេខ **131 450** ហើយស្នើសុំលេខ **1300 44 88 29**។

ប្រសិនបើអ្នកថ្លង់ ពិបាកស្ដាប់ឮ ឬមានការលំបាកក្នុងការនិយាយ ឬការទំនាក់ទំនង សូមចូលមើលគេហទំព័រ **accesshub.gov.au** ដើម្បីទទួលបានជំនួយ។



# តើមានបណ្ដឹងតវ៉ាពន្ធដារឬ?

យើងជួយធ្វើឱ្យប្រព័ន្ធពន្ធដារ និងប្រាក់សោធននិវត្តន៍របស់ប្រទេសអូស្ត្រាលីមានភាពយុត្តិធម៌។

យើងពិនិត្យមើលបណ្ដឹងតវ៉ាអំពីការិយាល័យពន្ធដារអូស្ត្រាលី (ATO) និងក្រុមប្រឹក្សាភិបាលអ្នកអនុវត្តវិជ្ជាជីវៈពន្ធដារ (TPB) ហើយជួយដោះស្រាយបណ្ដឹងតវ៉ាទាំងនោះ។

Khmer | ភាសាខ្មែរ

Tax Ombudsman



# របៀបធ្វើបណ្តឹងតវ៉ា

អ្នកត្រូវតែបានប្តឹងតវ៉ាទៅ ATO ឬ TPB រួចហើយ មុននឹងយើងអាចជួយអ្នកបាន។

ដើម្បីធ្វើបណ្តឹងតវ៉ា សូមចូលមើលគេហទំព័រ **taxombudsman.gov.au** ហើយជ្រើសរើស "**ដាក់បណ្តឹងតវ៉ា**"។

មន្ត្រីស៊ើបអង្កេតនឹងទាក់ទងអ្នកក្នុងរយៈពេល 2 ថ្ងៃធ្វើការ ដើម្បីបញ្ជាក់បណ្តឹងតវ៉ារបស់អ្នក ហើយនិយាយជាមួយអ្នកអំពីជំហានបន្ទាប់។

# របៀបដែលយើងអាចជួយអ្នក

អ្នកអាចទាក់ទងមកយើង ប្រសិនបើអ្នកជឿជាក់ថា ATO ឬ TPB បានប្រព្រឹត្តចំពោះអ្នកដោយអយុត្តិធម៌ ឬមិនសមហេតុផល។ យើងអាចជួយជាមួយនឹងបណ្តឹងតវ៉ានានាអំពី៖

- ការពន្យារពេលក្នុងរឿងប្រាក់ពន្ធបង្វិលសងវិញ ឬការទូទាត់ប្រាក់
- សេវាកម្មមិនល្អ ឬការប្រព្រឹត្តដោយអយុត្តិធម៌
- បំណុលពន្ធ ឬការប្រមូលបំណុល
- ផែនការទូទាត់ប្រាក់ ឬការគិតការប្រាក់
- ការរៀបចំការលំបាកផ្នែកហិរញ្ញវត្ថុ
- ការបាត់បង់ប្រាក់សោធននិវត្តន៍
- បំណុលពន្ធក្រុមហ៊ុន ឬការជូនដំណឹងអំពីការពិន័យនាយក។

សេវាកម្មរបស់យើងគឺឥតគិតថ្លៃ និងឯករាជ្យ។

ប្រសិនបើអ្នកមិនប្រាកដថាយើងអាចជួយបានឬអត់ សូមទាក់ទងមកយើង។

ប្រសិនបើបញ្ហារបស់អ្នកនៅក្រៅតួនាទីរបស់យើង យើងនឹងព្យាយាមណែនាំអ្នកទៅកាន់អង្គការត្រឹមត្រូវសម្រាប់ជំនួយ។

យើងមិនអាចផ្តល់ដំបូន្មានលើលិខិតប្រកាសពន្ធរបស់អ្នក ឬចំនួនពន្ធដែលអ្នកជំពាក់បានទេ។